TWR WOMEN OF HOPE

# ស្ត្រីក្នុងក្តីសង្ឃឹម
## ប្រតិទិនសំណូមអធិស្ឋាន

2026년 5월

ប្រតិទិនអធិស្ឋានចេញផ្សាយជារៀងរាល់ខែ ដែលមានជាង 100ភាសា និងមានអ្នកចូលរួមអធិស្ឋានជាង 110,000នាក់



### អធិស្ឋានសម្រាប់តំបន់អាហ្វ្រិកខាងកើត និង ភាគខាងត្បូង

នៅតាមតំបន់ទីហ្គ្រាយ សូម៉ាលី និងអាហ្វា នៃប្រទេសអេត្យូពី ស្ត្រីៗកំពុងតែរស់នៅក្នុងជីវិតដ៏ឈឺចាប់វេទនា ដោយសារតែជម្លោះមិនចេះចប់មិនចេះហើយ ទំនៀមទម្លាប់ដែលបង្កគ្រោះថ្នាក់ និង ការខ្វះខាតទឹកយ៉ាងធ្ងន់ធ្ងរដែលបណ្តាលមកពីគ្រោះរាំងស្ងួត។ ស្ត្រីនៅក្នុងតំបន់ទីហ្គ្រាយរងទុក្ខដោយសារស្នាមរបួសយ៉ាងជ្រៅពីសង្គ្រាម អំពើហិង្សា និង សេចក្តីទុក្ខសោកនៃការបាត់បង់ផ្ទះសម្បែងរបស់ពួកគេ។ នៅក្នុងតំបន់សូម៉ាលី ស្ត្រីៗគ្មានពេលសម្រាប់ជីវិតផ្ទាល់ខ្លួនឡើយ ព្រោះពួកគេត្រូវចំណាយពេលពេញមួយថ្ងៃដើម្បីដើររកទឹក និងអុស ព្រមទាំងត្រូវតស៊ូជាមួយនឹងជម្លោះរវាងកុលសម្ព័ន្ធ និង ការរៀបការទាំងវ័យក្មេងផងដែរ។ ស្ត្រីនៅក្នុងតំបន់អាហ្វាក៏កំពុងតស៊ូដើម្បីរស់នៅចំពេលដែលមានការប៉ះទង្គិចគ្នារវាងកុលសម្ព័ន្ធ និង គ្រោះរាំងស្ងួតដែលកើតមានជាបន្តបន្ទាប់។

ក្រុមការងារស្ត្រីនៃសេចក្តីសង្ឃឹមប្រចាំតំបន់អាហ្វ្រិក បានចុះទៅដល់ភូមិដាច់ស្រយាលទាំងនេះដោយផ្ទាល់ ដើម្បីចែកចាយវិទ្យុតូចៗដែលដើរដោយថាមពលព្រះអាទិត្យ និង ផ្សព្វផ្សាយពន្លឺនៃព្រះគ្រីស្ទតាមរយៈកម្មវិធីវិទ្យុរបស់ពួកគេ។ សូមឱ្យស្ត្រីនៅក្នុងប្រទេសអេត្យូពីបានជួបជាមួយព្រះយេស៊ូវគ្រីស្ទ បំបែកច្រវាក់នៃសេចក្តីអស់សង្ឃឹម និងស្វែងរកឃើញសេចក្តីសង្ឃឹមពិត នៅពេលដែលព្រលឹងរបស់ពួកគេត្រូវបានប្រែជាថ្មី។

카카오톡 채널에서 '소망의 여인들' 채널을 추가하시면 매주 월요일에 기도카드를 받으실 수 있습니다.

**៤**. ឱព្រះវរបិតាអើយ សូមឱ្យប្តីប្រពន្ធនៅប្រទេសអេស៊ីវ៉ាទីនី អោយតម្លៃដល់ការតាំងសញ្ញានៃអាពាហ៍ពិពាហ៍របស់ពួកគេ ហើយជ្រើសរើសដោះស្រាយការខ្វែងគំនិតគ្នា ដើម្បីកុំឱ្យក្រុមគ្រួសារត្រូវបែកបាក់ដោយសារការរស់នៅបែកគ្នា ឬ ការលែងលះ។ (អេភេសូរ ៥:៣១-៣៣)

**៥**. ព្រះជាម្ចាស់អើយ សូមពង្រឹងកម្លាំងដល់អ្នកជឿនៅប្រទេសអេត្យូពី ដែលកំពុងរងការបៀតបៀនដោយសារជំនឿរបស់ពួកគេ។ សូមឱ្យពួកគេបានរួមចំណែកក្នុងទុក្ខលំបាកជាមួយព្រះយេស៊ូវ ហើយរកឃើញព្រះគុណដើម្បីឈរឱ្យមាំមួននៅក្នុងទ្រង់។ (១ពេត្រុស ៤:១៣-១៤)

**៦**. ព្រះអម្ចាស់អើយ សូមការពារស្ត្រីជនជាតិកេនយ៉ា ឱ្យរួចផុតពីអំពើហឹង្សា និង ការរំលោភបំពានលើយេនឌ័រ។ សូមប្រទានសេចក្តីក្លាហាន យុត្តិធម៌ និង ការប្រោសឱ្យជាដល់ពួកគេ ដ្បិតទ្រង់ជាទីពឹងជ្រក និង ជាបន្ទាយមាំមួនរបស់ពួកគេនៅគ្រាមានអាសន្ន។ (ទំនុកដំកើង ១៨:២)

**៧**. ព្រះអម្ចាស់អើយ សូមបំបាក់ច្រវាក់នៃអាពាហ៍ពិពាហ៍វ័យកុមារនៅក្នុងប្រទេសម៉ាដាហ្គាស្កា ខណៈដែលទ្រង់បើកទ្វារនៃការអប់រំសម្រាប់កុមារី និង ប្រទានពរដល់ពួកគេនូវប្រាជ្ញា និង គោលបំណងដ៏រឹងមាំ។ (ទំនុកដំកើង ១៣៨:៨)

**៨**. ព្រះជាម្ចាស់អើយ សូមការពារស្ត្រីនៅប្រទេសម៉ូរីស ឱ្យរួចផុតពីការជួញដូរមនុស្ស អំពើហឹង្សា និង ការកេងប្រវ័ញ្ច។ សូមនាំមកនូវយុត្តិធម៌យ៉ាងឆាប់រហ័ស ការប្រោសឱ្យជាយ៉ាងជ្រាលជ្រៅ និង សន្តិភាពដ៏ស្ថិតស្ថេរតាមរយៈសេចក្តីស្រឡាញ់ដ៏មានព្រះចេស្តារបស់ទ្រង់។ (ទំនុកដំកើង ៣៤:១៨)

**៩**. ឱព្រះវរបិតាអើយ ក្នុងព្រះនាមព្រះយេស៊ូវ សូមប្រោសប្រទេសអាហ្វ្រិកខាងត្បូង ឱ្យរួចពីផ្នត់គំនិតបុរសជាធំដែលបង្កគ្រោះថ្នាក់នាំឱ្យស្ត្រីមានគ្រោះថ្នាក់ និង រឹតត្បិតសុវត្ថិភាព សុខភាព និង សេរីភាពសេដ្ឋកិច្ចរបស់ពួកគេ។ (កាឡាទី ៣:២៨)

**១០**. ព្រះជាម្ចាស់អើយ សូមនាំមកនូវការប្រោសឱ្យជាសម្រាប់ស្ត្រីនៅក្នុងប្រទេសតង់ហ្សានី ដែលកំពុងរងទុក្ខដោយសារជំងឺ របួសផ្លូវចិត្ត និង របួសខាងវិញ្ញាណ។ សូមឱ្យពួកគេរកឃើញសន្តិភាព និង សុខភាពនៅក្នុងទ្រង់។ (អេសាយ ៦១:១-៣)

**១១**. ព្រះអម្ចាស់អើយ សូមឱ្យស្ត្រីនៅប្រទេសបុតស្វាណា ស្គាល់ពីតម្លៃរបស់ពួកគេនៅក្នុងក្រសែភ្នែករបស់ទ្រង់។ សូមជួយឱ្យពួកគេអាចប្រើប្រាស់ទេពកោសល្យរបស់ពួកគេសម្រាប់ទ្រង់ និង ក្នុងនាមជាអ្នកដឹកនាំនៅក្នុងគ្រួសារ និង សហគមន៍របស់ពួកគេ។ (អេភេសូរ ២:១០)

**TWR Korea 북방선교방송**
서울특별시 관악구 양녕로 15, 월드빌딩 6층
전화 (02)886-5671 / 이메일 hskim@twrk.or.kr

**១២**. ព្រះអម្ចាស់អើយ
សូមបញ្ឈប់អំពើគួរស្អប់ខ្ពើមដែលក្មេងស្រីនៅប្រទេសអេស៊ីវ៉ាទីនី
ត្រូវបានរំលោភសេព សន្ធវៈ នៅពេលដែលពួកគេទៅរកពូ ឬ
សាច់ញាតិផ្សេងទៀតដើម្បីសុំជំនួយពីថ្លៃសាលា និង សម្ភារៈសិក្សា។
(ទំនុកដំកើង ៨២:៤)

**១៣**. ព្រះបន្ទូលរបស់ទ្រង់មានបន្ទូលថា ទ្រង់ដោះលែងប្រជារាស្ត្ររបស់ទ្រង់
«ឱ្យរួចពីសេចក្តីស្លាប់ ហើយថែរក្សាគេឱ្យរស់នៅក្នុងគ្រាអត់ឃ្លាន»។
ឱព្រះវរបិតាអើយ
សូមប្រទានការផ្គត់ផ្គង់ដល់កូនប្រុសកូនស្រីរបស់ទ្រង់នៅក្នុងតំបន់កេឡាហ្វូ
នៃប្រទេសសូម៉ាលី។ (ទំនុកដំកើង ៣៣:១៨-១៩)

**១៤**. ព្រះជាម្ចាស់អើយ សូមដោះលែងស្ត្រីអាហ្វ្រិកខាងត្បូង
ដែលត្រូវបានបណ្តុះបណ្តាលជាគ្រូព្យាបាលបុរាណ
ឱ្យរួចពីនគរនៃសេចក្តីងងឹតមកកាន់នគរនៃពន្លឺ និង ជីវិតរបស់ទ្រង់វិញ។
(កូឡូស ១:១៣)

**៥**. ព្រះអម្ចាស់អើយ សូមនាំមកនូវការបំបែកផ្នែកហិរញ្ញវត្ថុ ការងារ និង
ឱកាសអាជីវកម្មសម្រាប់ស្ត្រីនៅក្នុងប្រទេសតង់ហ្សានី
សូមប្រទានពរដល់ការងារដែលធ្វើដោយដៃរបស់ពួកគេ និង
បំបែកវដ្តនៃភាពក្រីក្រ។ (ភីលីព ៤:១៩)

**១៦**. ឱព្រះវរបិតាអើយ
យើងខ្ញុំអធិស្ឋានសុំការស្តារឡើងវិញនៃគ្រួសារនៅក្នុងប្រទេសបុតស្វាណា។
សូមឱ្យមានសន្តិភាព ការប្រស្រ័យទាក់ទងគ្នា និង
ការប្រោសឱ្យជាក្នុងគ្រប់ទំនាក់ទំនងទាំងអស់។ (រ៉ូម ១២:១៨)

**១៧**. ព្រះអម្ចាស់អើយ
យើងខ្ញុំអធិស្ឋានប្រឆាំងនឹងអំពើហឹង្សាលើយេនឌ័រនៅក្នុងប្រទេសអេស៊ីវ៉ាទីនី។
សូមឱ្យការសម្លាប់ស្ត្រីដោយមនុស្សជាទីស្រឡាញ់របស់ពួកគេបានបញ្ឈប់ក្នុង
ព្រះនាមព្រះយេស៊ូវ។ (សុភាសិត ១១:២៩)

**១៨**. ព្រះជាម្ចាស់អើយ
សូមនាំមកនូវសន្តិភាពដល់តំបន់ទីហ្គ្រៃនៃប្រទេសអេត្យូពី។
សូមធ្វើការក្នុងចិត្តរបស់អ្នកដឹកនាំឱ្យមានសន្តិភាព
ដើម្បីឱ្យការរងទុក្ខរបស់ប្រជាជនបានបញ្ឈប់។ (ទំនុកដំកើង ២៧:១-៣)

**១៩**. ព្រះអម្ចាស់អើយ
សូមបំបាត់ការរំពឹងទុកដែលបង្កគ្រោះថ្នាក់នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង
ដែលធ្វើឱ្យតម្លៃរបស់ស្ត្រីនៅលីវថយចុះ។
សូមឱ្យពួកគេស្គាល់ពីតម្លៃរបស់ពួកគេនៅក្នុងទ្រង់
ដើម្បីកុំឱ្យពួកគេមានអារម្មណ៍ថាត្រូវរងសម្ពាធក្នុងការរៀបការឡើយ។
(១កូរិនថូស៧)

**២០**. ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌
យើងខ្ញុំទូលសូមការការពារពីទ្រង់សម្រាប់ស្ត្រី និង កុមារីនៅក្នុងប្រទេស
តង់ហ្សានី ឱ្យរួចផុតពីការជួញដូរមនុស្ស ការកេងប្រវ័ញ្ច និង ការបោកបញ្ឆោត។
(ទំនុកដំកើង ១២៧:៧-៨)

**២១**. ព្រះអម្ចាស់អើយ សូមបំពាក់ឱ្យស្ត្រីនៅប្រទេសបុតស្វាណា
នូវកម្លាំង និង សេចក្តីថ្លៃថ្នូរ ដើម្បីឱ្យពួកគេអាចនិយាយ និង
ដើរដោយប្រាជ្ញា
ហើយប្រឈមមុខនឹងអនាគតដោយគ្មានការភ័យខ្លាច។ (សុភាសិត
៣១:២៥)

**២២**. ឱព្រះវរបិតាអើយ យើងខ្ញុំអធិស្ឋានសម្រាប់កុមារនៅប្រទេសអេស៊ីវ៉ាទីនី
ដែលកំពុងរស់ក្នុងភាពក្រីក្រតោកយ៉ាក ដោយដឹកនាំគ្រួសារ និង
មានការទទួលខុសត្រូវដ៏ធ្ងន់ក្នុងការមើលថែរក្សាប្អូនៗរបស់ពួកគេ។
(សុភាសិត ១៩:១៧)

**២៣**. ព្រះជាម្ចាស់អើយ ទ្រង់គឺជាចៅក្រមដ៏យុត្តិធម៌
ហើយទ្រង់ទតឃើញស្ត្រីនៅក្នុងប្រទេសអេត្យូពី
ដែលកំពុងជួបប្រទះការសង្កត់សង្កិន។ ព្រះអម្ចាស់អើយ
សូមជួយការពារក្តីដល់ពួកគេ ដើម្បីឱ្យពួកគេទទួលបានយុត្តិធម៌។
(ទំនុកដំកើង ១០៣:៦)

**២៤**. ព្រះអម្ចាស់អើយ សូមដោះលែងស្ត្រីនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង
ដែលកំពុងត្រូវបានបោកបញ្ឆោតដោយបុរសកាន់សាសនាដ៏អាក្រក់
ដែលផ្សព្វផ្សាយព្រះបន្ទូលរបស់ទ្រង់ ប៉ុន្តែចិត្ត និង
ទង្វើរបស់ពួកគេនៅឆ្ងាយពីទ្រង់។ (ម៉ាថាយ ១៥:៨-៩)

**២៥**. ឱព្រះវរបិតាអើយ សូមមេត្តាការពារកុមារីនៅប្រទេសតង់ហ្សានី
ឱ្យរួចផុតពីអាពាហ៍ពិពាហ៍វ័យក្មេង និង ការមានផ្ទៃពោះក្នុងវ័យជំទង់
សូមរក្សាអនាគត និង ជោគវាសនារបស់ពួកគេនៅក្នុងទ្រង់។ (យេរេមា
២៩:១១)

**២៦**. ព្រះអម្ចាស់អើយ សូមនាំមកនូវស្ថិរភាពផ្លូវអារម្មណ៍ សន្តិភាពផ្លូវចិត្ត និង
សេរីភាពពីការថប់បារម្ភ ជំងឺបាក់ទឹកចិត្ត និង
ការភ័យខ្លាចក្នុងចំណោមស្ត្រីដែលកំពុងទទួលការប្រោសឱ្យជាពីរបួសផ្លូវចិត្ត
នៅកោះសាន់ស៊ីបា និង កោះពេមបា។ (ទំនុកដំកើង ៣៤:៤)

**២៧**. ឱព្រះវរបិតាអើយ សូមជួយឱ្យស្ត្រីនៅប្រទេសបុតស្វាណា
អាចឈរមាំមួននៅក្នុងទ្រង់ ខណៈដែលពួកគេឆ្លងកាត់ការលំបាក និង
ការថប់បារម្ភក្នុងជីវិត តាមរយៈព្រះគុណ និង ប្រាជ្ញារបស់ទ្រង់។ (យ៉ាកុប ១:៥)

**២៨**. ព្រះជាម្ចាស់អើយ ទ្រង់គ្រប់គ្រងលើអស់ទាំងសាសន៍។
យើងខ្ញុំអធិស្ឋានសុំឱ្យការបោះឆ្នោតក្នុងខែមិថុនា នៅប្រទេសអេត្យូពី
ប្រព្រឹត្តទៅដោយសន្តិវិធី និង យុត្តិធម៌។ សូមឱ្យអ្នកដឹកនាំដែលសុចរិត និង
យុត្តិធម៌ត្រូវបានជ្រើសរើស។ (សុភាសិត ២៩:៤)

**២៩**. ព្រះអម្ចាស់អើយ សូមនាំមកនូវយុត្តិធម៌ ការការពារ និង
ការស្តារឡើងវិញសម្រាប់ស្ត្រីអាហ្វ្រិកខាងត្បូង
ដែលត្រូវបានកេងប្រវ័ញ្ចដោយមនុស្សដែលគួរតែជាអ្នកគាំទ្រពួកគេ។ (និក្ខមនំ
១៤:១៤)

**៣០**. ព្រះជាម្ចាស់អើយ យើងខ្ញុំអធិស្ឋានសុំសន្តិភាព ការយោគយល់ និង
សេចក្តីស្រឡាញ់ក្នុងគ្រួសារ និងអាពាហ៍ពិពាហ៍នៅក្នុងប្រទេសតង់ហ្សានី។
សូមនាំមកនូវការប្រោសឱ្យជាត្រង់កន្លែងណាដែលមានទំនាក់ទំនងបែកបាក់។
(កូឡូស ៣:១៥)

**후원안내**
**국민은행 851-01-0003-724 북방선교방송**
**최초 입금 후 사무실로 연락주시기 바랍니다.**